# “អារម្មណ៍សោកសៅក្រោយសម្រាលកូន” និងជំងឺធ្លាក់ទឹកចិត្ត ក្រោយពេលសម្រាល



## តើ “អារម្មណ៍សោកសៅក្រោយសម្រាលកូន” គឺជាអ្វី?

“អារម្មណ៍សោកសៅក្រោយសម្រាលកូន” គឺនៅពេលដែលអ្នកមានអារម្មណ៍ទុក្ខព្រួយ និង "សោកសៅ" ក្នុងរយៈពេលពីរសប្តាហ៍ដំបូងបន្ទាប់ពីសម្រាលកូនហើយ។ អារម្មណ៍ទាំងនេះគឺជារឿងធម្មតា។

ម្តាយជាច្រើននាក់ប្រឈមនឹងការផ្លាស់ប្តូរនានាបន្ទាប់ពីសម្រាលកូនហើយ។

- រាងកាយរបស់អ្នកកំពុងព្យាយាមសម្របខ្លួននឹងការលែងមានផ្ទៃពោះ។
- កម្រិតអ័រម៉ូនរបស់អ្នកនឹងត្រឡប់ទៅធម្មតាវិញ។
- ទម្លាប់នៃការគេងរបស់អ្នកខុសពីធម្មតាខ្លាំង។
- ការទាមទារទៅលើពេលវេលា និងថាមពលរបស់អ្នកបានផ្លាស់ប្តូរ។

សួរអ្នកផ្តល់សេវារបស់អ្នកសម្រាប់ព័ត៌មានបន្ថែមអំពី "អារម្មណ៍សោកសៅក្រោយសម្រាលកូន"។

## តើជំងឺធ្លាក់ទឹកចិត្តក្រោយពេលសម្រាលកូនគឺជាអ្វី?

ប្រសិនបើការប្រែប្រួលនៃអារម្មណ៍របស់អ្នកមិនចាប់ផ្តើមបាត់ទៅវិញទេនោះ អ្នកអាចនឹងមានជំងឺធ្លាក់ទឹកចិត្តក្រោយពេលសម្រាលកូន។

រោគសញ្ញានៃជំងឺធ្លាក់ទឹកចិត្តក្រោយពេលសម្រាលកូនរួមមាន៖

- អ្នកមានអារម្មណ៍ធ្លាក់ទឹកចិត្តបីទៅបួនសប្តាហ៍ក្រោយកូនរបស់អ្នកសម្រាលហើយ។
- អ្នកមានអារម្មណ៍សោកសៅ អស់សង្ឃឹម និងថប់បារម្ភជាខ្លាំង។
- អ្នកមានអារម្មណ៍អស់កម្លាំង ឬបាត់បង់អស់ថាមពលក្នុងខ្លួន។
- អ្នកមិនអាចបញ្ចប់កិច្ចការប្រចាំថ្ងៃបាន។
- អ្នកលំបាកបង្កើតទំនាក់ទំនងជាមួយទារករបស់អ្នក។
- អ្នកខ្លាចថា អ្នកអាចធ្វើឱ្យខ្លួនអ្នក ឬទារករបស់អ្នកឈឺចាប់។
- អ្នកមិនមានអារម្មណ៍ធូរស្រាលនោះទេ ក្រោយមួយរយៈកាលមក។

ប្រសិនបើអ្នកសម្គាល់ឃើញសញ្ញាណាមួយក្នុងចំណោមសញ្ញាទាំងនេះ អ្នកប្រហែលជាត្រូវការជំនួយពិសេស។ ចូរពិភាក្សាជាមួយអ្នកផ្តល់សេវារបស់អ្នក។ គាត់ឬនាងអាចជួយអ្នកឱ្យទទួលបានការព្យាបាល។

ម្តាយមួយចំនួនត្រូវការថ្នាំដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍ធូរស្បើយមកវិញ។ ចូរលេបថ្នាំរបស់អ្នកតាមវេជ្ជបញ្ជាដែលចេញដោយអ្នកផ្តល់សេវារបស់អ្នក។

### សម្រាប់ការគាំទ្រផ្នែកសុខភាពផ្លូវចិត្តជាបន្ទាន់

សូមទូរសព្ទទៅបណ្តាញដំបូន្មានគិលានុបដ្ឋាយិការបស់យើងបាន 24 ម៉ោង។ ពួកយើងនៅទីនេះដើម្បីជួយអ្នក។

English: **(888) 275-8750**
Español: **(866) 648-3537**
TTY/TDD: **711**

ដើម្បីទទួលបានសេវាសុខភាពផ្លូវចិត្ត សូមទាក់ទងសេវាបម្រើសមាជិកតាមរយៈលេខ (888) 665-4621។ នាយកដ្ឋានសុខភាពអាកប្បកិរិយារបស់យើងនឹងទាក់ទងទៅអ្នកនៅក្នុងរយៈពេល 3 ថ្ងៃធ្វើការ។

### លេខប្រចាំការផ្នែកសុខភាពផ្លូវចិត្តរបស់ម្តាយថ្នាក់ជាតិ

ទូរសព្ទទៅរកការគាំទ្របន្ថែមតាមលេខ (833) 852-6262 ដើម្បីនិយាយជាមួយអ្នកប្រឹក្សាយោបល់ម្នាក់។

ដើម្បីទទួលបានព័ត៌មាននេះជាភាសា និងទម្រង់ដែលអាចប្រើបានផ្សេងទៀត សូមហៅទូរសព្ទទៅកាន់សេវាបម្រើសមាជិក។ លេខទូរសព្ទនេះគឺនៅផ្នែកខាងក្រោយនៃបណ្ណសម្គាល់សមាជិករបស់អ្នក។

**MolinaHealthcare.com**
34041FLYMDCAKM | 250905